# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មហានគរ ម.ក
MOHANOKOR Microfinance Institution Plc.

## ដំណឹងជ្រើសរើសបុគ្គលិក

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មហានគរ ម.ក** គឺជាគ្រឹះស្ថានឯកជន ដែលផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដល់ប្រជាជនកម្ពុជា ជាមួយនឹងតំបន់ប្រតិបត្តិការទូទាំង ២៥ខេត្តក្រុង និងរាជធានី ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ ។ ឆ្លើយតបទៅនឹងការរីកចម្រើនជាបន្តបន្ទាប់ គ្រឹះស្ថានត្រូវការជ្រើសរើស **ប្រធានទំនាក់ទំនង (Relationship Manager )** ចំនួន **០៣ នាក់** សម្រាប់បម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មហានគរ ម.ក **សាខាស្រុកត្បូងឃ្មុំ សាខាខេត្តមណ្ឌលគិរី និងសាខាខណ្ឌច្បារអំពៅ** ។

| តួនាទី និងភារកិច្ចទទួលខុសត្រូវ | លក្ខខណ្ឌនៃការជ្រើសរើស |
|---|---|
| -ចូលរួមធ្វើផែនការយុទ្ធសាស្ត្រ ផ្តល់ឥណទាន ប្រាក់បញ្ញើសន្សំ និងសេវាផ្សេងៗ រយៈពេលវែង ប្រចាំឆ្នាំ ប្រចាំខែ និងប្រចាំសប្តាហ៍។<br>-ចូលរួមត្រួតពិនិត្យផែនការយុទ្ធសាស្ត្រអាជីវកម្មក្នុងរយៈពេលវែងនៃការផ្តល់ឥណទានសម្រាប់ផែនការប្រចាំខែ និងប្រចាំឆ្នាំ។<br>-ចូលរួមធ្វើផែនការយុទ្ធសាស្ត្រហិរញ្ញវត្ថុ ប្រចាំសប្តាហ៍ (សាច់ប្រាក់) និងប្រចាំខែ។<br>-ចូលរួមរៀបចំផែនការជ្រើសរើសបុគ្គលិក និងរៀបចំផែនការគ្រប់គ្រងប្រតិបត្តិការ។<br>-ចូលរួមសិក្សា និងវាយតម្លៃ តំបន់ ប្រតិបត្តិការថ្មី និងចាស់ (ស្រុក/ខណ្ឌ ឃុំ/សង្កាត់ និងភូមិ) ផ្សព្វផ្សាយនូវផលិតផល-សេវាកម្ម ឥណទាន និងប្រាក់បញ្ញើសន្សំ។<br>-រៀបចំ ចាត់ចែង និងត្រួតពិនិត្យលើផែនការបញ្ចេញ-ប្រមូលឥណទានប្រចាំថ្ងៃរបស់មន្ត្រីទំនាក់ទំនងដាក់ជូន ថ្នាក់មានសមត្ថកិច្ច ឬផ្នែកពាក់ព័ន្ធ។<br>-ដឹកនាំ ចាត់ចែង និងសិក្សាស្រាវជ្រាវ ទៅលើប្រវត្តិអតិថិជន អត្តចរិត ទ្រព្យធានា សមត្ថភាពសងត្រលប់ និងស្របតាមលក្ខខណ្ឌរបស់គ្រឹះស្ថាន។<br>-ធ្វើការត្រួតពិនិត្យរាល់ឯកសារ និងជួយបំពេញទៅលើឯកសារឥណទាន និងព្រមទាំងប្រាក់បញ្ញើសន្សំ។<br>-ធានាបាននូវការគោរពគោលការណ៍និតិវិធី និងអនុវត្តតាមការណែនាំផ្សេងៗរបស់នាយកសាខា នាយកតំបន់ និងការិយាល័យកណ្តាល។ | - កម្រិតបរិញ្ញាបត្រជំនាញ ធនាគារ និងហិរញ្ញវត្ថុ សេដ្ឋកិច្ចអាជីវកម្ម ឬជំនាញពាក់ព័ន្ធផ្សេងទៀត។<br>- យ៉ាងតិចមានបទពិសោធន៍ ២ឆ្នាំទាក់ទងនឹងការគ្រប់គ្រង។<br>- មានការបង្កើតស្នាដៃថ្មីៗ ភាពលេចធ្លោ សមត្ថភាពគ្រប់គ្រង និងផលិតភាពការងារបានល្អប្រសើរ។<br>- មានភាពវៃឆ្លាត គំនិតឆ្នៃប្រឌិតខ្ពស់ មានការវិភាគជ្រៅជ្រះ។<br>- មានចំណេះដឹងខាងផ្នែកបច្ចេកទេសដូចជា Ms. Word, Excel, Powerpoint, Email, …។<br>- មានទំនាក់ទំនងល្អគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ និងបង្កើនភាពទុកចិត្ត។<br>- មានភាពស្មោះត្រង់ សុខភាពល្អ មានឆន្ទៈខ្ពស់ មានភាពអត់ធ្មត់ ផែនការទិសដៅនិងចក្ខុវិស័យ។ |

| អត្ថប្រយោជន៍ទទួលបាន | |
|---|---|
| - ប្រាក់បៀវត្សខ្ពស់ និងប្រកួតប្រជែងជាមួយទីផ្សារការងារបច្ចុប្បន្ន | - ប្រាក់បុព្វលាភសម្រាប់បុណ្យចូលឆ្នាំប្រពៃណី និងបុណ្យភ្ជុំបិណ្ឌ |
| - ប្រាក់ជួលម៉ូតូ និងឧបត្ថម្ភសាំងប្រចាំខែ | - ប្រាក់រំលឹកអតីតភាពការងារ |
| - ប្រាក់រង្វាន់លើកទឹកចិត្តប្រចាំខែ | - ប្រាក់កម្ចីបុគ្គលិកក្នុងអត្រាការប្រាក់សមរម្យ |
| - វិភាជន៍ប្រាក់ចំណេញប្រចាំឆ្នាំ | - ធានារ៉ាប់រងលើហានិភ័យការងារ |
| - ប្រាក់ឧបត្ថម្ភលើការសិក្សាជំនាញ | - ការតម្លើងប្រាក់បៀវត្សប្រចាំឆ្នាំ |
| - ការបណ្តុះបណ្តាលជំនាញបន្ថែម | - ធានារ៉ាប់រងលើសេវាថែទាំសុខភាព និងហានិភ័យការងារ |
| - ប្រាក់ឧបត្ថម្ភតំបន់ | - ធានារ៉ាប់រងលើអាយុជីវិត |
| - ប្រាក់ឧបត្ថម្ភលំហែមាតុភាព | - ប្រាក់សោហ៊ុយធ្វើដំណើរ |
| - ប្រាក់ឧបត្ថម្ភបេសកកម្មក្នុង និងក្រៅប្រទេស | - អត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀត តាមគោលការណ៍កំណត់ |

### ឯកសារភ្ជាប់ និងការទំនាក់ទំនង

ពាក្យសុំបម្រើការងារចែកជូនដោយ***ឥតគិតថ្លៃ*** នៅការិយាល័យកណ្តាល គ្រប់បណ្តាសាខាទូទាំងខេត្តក្រុង និងគេហទំព័ររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មហានគរ ម.ក ដោយភ្ជាប់មកជាមួយនូវឯកសារថតចម្លងដូចជា៖ **សញ្ញាបត្រ, អត្តសញ្ញាណប័ណ្ណ ,សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ ប័ណ្ណ-បើកបរ និងលិខិតបញ្ជាក់ផ្សេងៗ ។**

**ការិយាល័យកណ្តាល ៖** អគារលេខ២៤ មហាវិថីយុទ្ធពលខេមរភូមិន្ទ(២៧១) សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

Telephone/Telegram: 087 999 291/ 87 999 221 ឬ **E-mail:** recruitment@mohanokor.com

គេហទំព័រ ៖ www.mohanokor.com , គេហទំព័រសង្គម(Facebook) ៖ Mohanokor Microfinance Institution Plc.

*សូមអរគុណ!*